00414535

លេខ/No: D275

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 12 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA. Tey

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

កំណត់ហេតុនៃការស្តាប់ចម្លើយជនត្រូវចោទ
**Written Record of Interview of Charged Person**
**Procès-verbal d'interrogatoire**

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 15 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA. Tey

ឆ្នាំពីរពាន់ប្រាំបួន ខែធ្នូ ថ្ងៃទីដប់បួន នៅវេលាម៉ោងប្រាំបួន និងដប់ប្រាំនាទី

យើង **យូ ប៊ុនឡេង** និង Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានលោក ហម ហ៊ែល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៥ និង ៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានវត្តមានរបស់ អ៊ុច ចាន់ណូរ៉ា និង បែល សក្តិភក្តី ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលបានស្បថរួចហើយ។

ជនត្រូវចោទដែលមានអត្តសញ្ញាណដូចខាងក្រោម បានចូលខ្លួនទៅចំពោះមុខយើង:

ឈ្មោះខ្លួន **ជា** គេទ ប្រុស កើតថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦

ត្រូវដាក់ឱ្យឋិតក្រោមការពិនិត្យលើ **បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការបំពារបំពានធ្ងន់ធ្ងរលើ** **អនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
*Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941*

បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ លោក Andrew Cayley និង អ្នកស្រី **ជា លាង** (CHEA Leang) ដែលត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះ នៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ៖

☒ អ្នកស្រី **ជា លាង** CHEA Leang ត្រូវបានតំណាងដោយលោក **សេង ប៊ុនឃាង** Seng Bunkheang ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា។

☒ លោក Andrew Cayley ត្រូវបានតំណាងដោយលោក Dale C. Lysak ជំនួយការរបស់សហព្រះរាជអាជ្ញា។

លោកមេធាវី **សុន អរុណ** Son Arun និង Michiel Pestman សហមេធាវីរបស់ជនត្រូវចោទ ត្រូវបានកោះអញ្ជើញ នៅក្នុងដីកាកោះ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ និង មានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក លោកមេធាវី សុន អរុណ Son Arun វត្តមាន។ លោកមេធាវី Michiel Pestman អវត្តមាន។

## ការសួរចម្លើយ

### សេចក្តីថ្លែងរបស់សហចៅក្រមស៊ើបអង្កេត

១. នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ អនុលោមតាមសំណើសុំរបស់សហព្រះរាជអាជ្ញា[1] យើងបានចេញដីកាសម្រេចមួយ[2] ដែលក្នុងនោះ យើងបានព្យាយាមបញ្ជាក់បំភ្លឺអំពីការបកស្រាយបទប្បញ្ញត្តិនៃ

[1] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺអំពីបទចោទ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៨, D198។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

វិធានផ្ទៃក្នុង ទាក់ទងនឹងការដាក់ឲ្យឋិតក្រោមការពិនិត្យ។ ជាពិសេស យើងបានបញ្ជាក់រួចហើយថា នៅពេលដែលមានការសម្រេចដាក់ឲ្យឋិតក្រោមការពិនិត្យ សេចក្ដីជូនដំណឹងអំពី “អង្គហេតុដែលចោទប្រកាន់” (faits reprochés/material facts) ទាមទារឲ្យមានការបញ្ជាក់អំពីការកំណត់ប្រភេទបទល្មើស និងគួរចងចាំទុកថា ការកំណត់ប្រភេទបទល្មើសនេះ គឺគ្រាន់តែមានលក្ខណៈបណ្ដោះអាសន្ន ប៉ុណ្ណោះនៅក្នុងដំណាក់កាលស៊ើបសួរ។ យើងក៏បានបញ្ជាក់ផងដែរថា នៅក្នុងការតាក់តែងដីកាដំណោះស្រាយ យើងមានកាតព្វកិច្ចក្នុងការកំណត់ប្រភេទបទល្មើសលើគ្រប់អង្គហេតុទាំងអស់ដែលត្រូវបានប្ដឹងមក តាមរយៈការចេញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ឬដីកាលើកលែងការចោទប្រកាន់[3]។

២. ការស្ដាប់ចម្លើយនេះត្រូវបានរៀបចំឡើងដោយគោរពតាមគោលការណ៍ខាងលើនេះ។ ដោយសារថាការស៊ើបសួរកំពុងខិតទៅរកទីបញ្ចប់ទៅហើយនោះ និងដើម្បីធ្វើការជូនដំណឹងដល់លោកអំពីអង្គហេតុ ដែលលោកអាចនឹងត្រូវបានបញ្ជូនទៅជំនុំជម្រះនៅត្រឹមដំណាក់កាលស៊ើបសួរនេះ សូមចងចាំទុកថា *“ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះចំពោះអង្គហេតុណាដែលបុគ្គលនោះមិនត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យជាមុននោះទេ នោះការដាក់ឲ្យឋិតក្រោមការពិនិត្យមិនមែនជាបុរេវិនិច្ឆ័យនៃសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ នៅក្នុងដំណាក់កាលនៃការបិទការស៊ើបសួរនោះឡើយ។”*[4]

៣. ដោយពិនិត្យលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមជាបន្តបន្ទាប់ សហចៅក្រមស៊ើបអង្កេតកំពុងត្រៀមបញ្ចប់ការស៊ើបសួរលើអង្គហេតុដែលប្ដឹងមក

---

[2] ដីការសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើការបក្អីអំពីបទចោទ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩, D198/1។

[3] ដដែល មើលកថាខណ្ឌ ១០។

[4] ដដែល មើលកថាខណ្ឌទី១០។

និងលើការទទួលខុសត្រូវរបស់ជនត្រូវចោទ ចំពោះបទឧក្រិដ្ឋនានាដែលត្រូវបានរកឃើញនៅត្រឹមដំណាក់កាលនេះ។

៤. ឆ្លងតាមរយៈការពិនិត្យលើភស្តុតាងដែលទទួលបានពីសហករណ៍ និងការដ្ឋាននានា មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់នានា ស្ថានភាពនៃការជម្លៀសប្រជាជន និងការប្រព្រឹត្តលើក្រុមជនជាតិ ឬសាសនាផ្សេងៗ ដូចជា ចាម វៀតណាម ពុទ្ធសាសនិក និងក្រុមសម្ព័ន្ធដីទៃផ្សេងៗទៀត យើងអាចវាយតម្លៃបានថា វាពិតជាមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បានបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មក្នុងបទល្មើសជាតិ ពិតជាត្រូវបានប្រព្រឹត្តឡើង។

៥. នៅត្រឹមដំណាក់កាលស៊ើបសួរនេះ សហចៅក្រមស៊ើបអង្កេតក៏កត់សម្គាល់ផងដែរថា វាពិតជាមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បានបង្ហាញថា ក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជនត្រូវចោទឈ្មោះ នួន ជា ឬឈ្មោះហៅក្រៅជាច្រើនទៀតរួមមាន បង នួន សមមិត្ត នួន ឬ អ៊ំ នួន ឬបង ឬអ៊ំទី២ ធ្លាប់ជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជនដែលទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ក្នុងចំណោមជនផ្សេងទៀត ចំពោះឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក.។

៦. នៅក្នុងតួនាទីលោកជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក ជាប្រធានសភាតំណាងប្រជាជនកម្ពុជារបស់របបកម្ពុជាប្រជាធិបតេយ្យ និងជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ឬជានាយករដ្ឋមន្ត្រីស្តីទី លោកបានចូលរួមក្នុងការបង្កើត ការអនុវត្ត ឬការសម្របសម្រួលអោយមានគោលនយោបាយ ប.ក.ក ដែលគោលនយោបាយនេះបណ្តាលឲ្យមានការជម្លៀសប្រជាជន ការបង្កើតនិងការដាក់ឲ្យដំណើរការសហករណ៍ និងការដ្ឋាននានា ការបង្កើតនិងការដាក់ឲ្យដំណើរការមន្ទីសន្តិសុខ និងទីកន្លែងសម្លាប់នានា ព្រមទាំងការធ្វើទុក្ខបុកម្នេញលើជនស៊ីវិល រាប់បញ្ចូលទាំងជនជាតិចាម វៀតណាម និងពុទ្ធសាសនិក និងក្រុមមនុស្សផ្សេងទៀត។ បន្ថែមពីលើនេះ

នៅក្នុងតួនាទីទាំងនោះ លោកធ្លាប់សហការ និងចូលរួមប្រជុំកំរិតខ្ពស់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្នែកយោធា និងនយោបាយផ្សេងៗទៀតរបស់ ប.ក.ក ក៏ដូចជាជាមួយសមាជិកគណៈភូមិភាគ និងតំបន់ និងមេបញ្ជាការយោធា។ ក្នុងពេលកិច្ចប្រជុំទាំងនោះ និងតាមរយៈការទទួលបានទូរលេខ របាយការណ៍ ចម្លើយសារភាព និងលិខិតទំនាក់ទំនងដ៏ទៃទៀត ហើយតាមរយៈការចុះធ្វើទស្សនកិច្ចនៅតាមការដ្ឋាន នានា និងក្រសួងនានា ព្រមទាំងអង្គភាពផ្សេងៗទៀតរបស់មជ្ឈិម និងទីកន្លែងផ្សេងៗ ទៀតទូទាំងប្រទេស លោកត្រូវបានជូនដំណឹងអំពីស្ថានភាពនៅក្នុងទីក្រុងភ្នំពេញ និងស្ថានភាពនានា នៅក្នុងប្រទេសកម្ពុជាទាំងមូល និងអំពីស្ថានភាពនៅតាមបណ្តោយព្រំដែន និងរួមទាំងរបៀបដែល គោលនយោបាយរបស់បក្សកុម្មុនីសកម្ពុជាត្រូវបានបង្កើត ផ្សព្វផ្សាយ និងអនុវត្តផងដែរ។

៧. ក្នុងឋានៈលោកជាអនុលេខា ប.ក.ក ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក ជាសមាជិកគណៈកម្មាធិការយោធារបស់ ប.ក.ក និងក្នុងតួនាទីផ្សេងទៀត លោកទទួលខុសត្រូវ ឬគ្រប់គ្រងបញ្ហាសន្តិសុខ សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ នៅក្នុងប្រទេសកម្ពុជា។ ដោយខ្លួនលោកផ្ទាល់ ឬតាមរយៈ សុន សេន លោកប្រើប្រាស់អំណាច ឬគ្រប់គ្រងដោយប្រសិទ្ធិភាពទៅលើ មន្ទីរសន្តិសុខ ស-២១ ក្រសួងនានា និងអង្គភាពយោធា និងអង្គភាពគ្រប់គ្រងដ៏ទៃទៀតរបស់មជ្ឈិម និងនៅក្នុងប្រទេសកម្ពុជាទាំងមូល។ លោកបានបញ្ជា អនុវត្តឬសម្របសម្រួលការចាប់ខ្លួន ការឃុំឃាំង ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់មនុស្សដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ជាពិសេសបុគ្គល ឬកម្មាភិបាលទាំងឡាយណាដែលត្រូវបានគេកំនត់ថាជា “សមាសភាពមិនល្អ” “ជនក្បត់” និង “ខ្មាំង” នៅក្នុងបក្ស ក្នុងកងទ័ពបដិវត្តន៍កម្ពុជា និង ក្នុងមន្ទីរនានាចំណុះមជ្ឈិមបក្សដូចជាមន្ទីរ៨៧០ និង ស-៧១ ក្រសួងនានា រាប់បញ្ចូលទាំងក្រសួងឃោសនាការ និងសង្គមកិច្ច និងប្រជាជនស៊ីវិល ឬទាហាន វៀតណាម។ ជាពិសេស លោកមានទំនាក់ទំងរវាងមន្ទីរសន្តិសុខ ស-២១ និងអង្គភាពរដ្ឋបាល និងយោធាដ៏ទៃទៀតនៅថ្នាក់ភូមិភាគ និងតំបន់ នៅមន្ទីរនានារបស់មជ្ឈិមបក្ស និងក្រសួងនានា ដើម្បីសម្រួលការចាប់ខ្លួនអ្នកទាំងនោះ។

៨. លោកបានចូលរួមនៅក្នុងការគាំទ្រ និងផ្សព្វផ្សាយនយោបាយរបស់ ប.ក.ក ទាំងក្នុងប្រទេស និងក្រៅប្រទេស។ ជាពិសេសលោកធ្លាប់ទទួលបន្ទុកការងារ ប.ក.ក ក្នុងវិស័យសង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ ហើយលោកបានពង្រឹង និងផ្សព្វផ្សាយនយោបាយ និងមនោគមវិជ្ជារបស់ ប.ក.ក តាមរយៈការចូលរួម និងបង្រៀនវគ្គសិក្សា និងអប់រំនយោបាយ និងមនោគមវិជ្ជាជាច្រើន។

៩. លោកបានចូលរួមក្នុងការបង្កើត ការអនុវត្ត ឬការសម្របសម្រួល និងការផ្សព្វផ្សាយគោលនយោបាយរបស់ ប.ក.ក ដែលពាក់ព័ន្ធនឹងសន្តិសុខក្រៅប្រទេស ហើយជាពិសេសទាក់ទិននឹងជម្លោះប្រដាប់អាវុធជាអន្តរជាតិជាមួយនឹងវៀតណាម ដែលបានពាក់ព័ន្ធនឹងអំពើប្រព្រឹត្តដែលបង្កើតបានជាការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩។

១០. ក្នុងស្ថានភាពលើកឡើងខាងលើ យើងសូមបញ្ជាក់លោកថា លោកត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់រួចមកហើយ នាពេលបង្ហាញមុខជាលើកដំបូង ហើយបន្ទាប់ពីបានពិនិត្យទៅលើភស្តុតាងរួចមក ឥឡូវនេះ យើងយល់ថាការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបន្ថែមទៀត ត្រូវតែធ្វើការជូនដំណឹងដល់លោកជាចាំបាច់។ ដូចនេះ តាមរយៈអំពើសកម្ម ឬអំពើអកម្មរបស់លោក លោកត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះ៖

- ការរៀបចំផែនការ
- ការញុះញង់
- ការបញ្ជា
- ការប្រព្រឹត្ត
- ការជួយនិងជម្រុញ
- សមគំនិត

00414541



- ការចូលរួម

- ការប៉ុនប៉ង

- និងក្នុងផែនអនុវត្តន៍ដែលបានកំណត់ដោយបញ្ញត្តិដែលមាននៅក្នុងដីការបស់យើង ស្តីពី "សហឧក្រិដ្ឋកម្មរួម"[5] លោកគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សផ្សេងទៀតដែលបានចូលរួមចំណែកនៅក្នុងផែនការរួមដែលបានពាក់ព័ន្ធ ឬនាំឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន

- ជាអ្នកទទួលខុសត្រូវក្នុងឋានៈជាថ្នាក់លើ

សម្រាប់បទឧក្រិដ្ឋដូចខាងក្រោម៖

**១១. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើឲ្យទៅជាទាសករ
- ការនិរទេស
- ការធ្វើទារុណកម្ម
- ការរំលោភផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា
- អំពើអមនុស្សធម៌ផ្សេងៗទៀត

[5] ដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការអនុវត្តទម្រង់នៃការទទួលខុសត្រូវ "សហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, D97/13។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៥១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00414542

លេខ/No: ១២៧៥

បទល្មើសដែលមានចែង និងផ្ដន្ទាទោសដោយ មាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ឆ្នាំ ២០០៤ *ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

**១២. ការបំពានបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩**

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការបំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌
- ការនិរទេស ឬ ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

បទល្មើសដែលមានចែង និងផ្ដន្ទាទោសដោយ មាត្រា ៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ឆ្នាំ ២០០៤ *ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

**១៣. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជនជាតិចាម និងវៀតណាម**

បទល្មើសដែលមានចែង និងផ្ដន្ទាទោសដោយ មាត្រា ៤ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ឆ្នាំ ២០០៤ *ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

១៤. លើសពីនេះទៀត ដោយពិចារណាទៅលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅក្នុង *សាលដីកា លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

*ហៅ ឌុច*[6] និងនៅរង់ចាំសេចក្តីសម្រេចលើបញ្ហានេះ យើងជូនដំណឹងលោកថា លោកក៏ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋដូចខាងក្រោមដែរ៖

**បទឧក្រិដ្ឋជាតិ**

- មនុស្សឃាត
- ទារុណកម្ម
- ការវាយប្រហារលើសាសនា

បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយ មាត្រា ៣ (ថ្មី) មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ឆ្នាំ ២០០៤ *ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* និងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

ក្រោយពីបានស្តាប់ការជូនដំណឹងទាំងអស់នេះ តើលោកមានការកត់សម្គាល់ទេ ឬ តើលោកចង់បន្តអនុវត្តសិទ្ធិនៅស្ងៀមរបស់លោកដដែល?

**ជនត្រូវចោទ:** ខ្ញុំ សុំប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ខ្ញុំដដែល។

☒ ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសម្លេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និង មេធាវីរបស់ជននេះ និង ត្រូវបានចុះហត្ថលេខាដោយ យើង ក្រឡាបញ្ជីសហព្រះរាជអាជ្ញា ជនត្រូវចោទ និង មេធាវីរបស់ជននេះ។

[6] *សាលដីកា លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច* D99/3/42 សំណុំរឿង ០០១/១៨-០៧-២០០៧ កថាខ័ណ្ឌ ៥៥-៨៨

00414544

លេខ/No: D275

☒ ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសម្លេង ត្រូវបានប្រគល់ឱ្យជនត្រូវចោទនេះ។

នៅវេលាម៉ោងប្រាំបួននិងសាមសិបប្រាំពីរនាទីគត់ យើងបានឱ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុស្តួរចម្លើយរបស់ជនត្រូវចោទនេះ ទៅតាមអ្វីដែលបានកត់ត្រា។

☒ អានឱ្យស្តាប់ហើយ ជនត្រូវចោទ មិនមានជំទាស់អ្វីទេ ហើយ សុខចិត្តចុះហត្ថលេខា។

| ជនត្រូវចោទ | មេធាវីជនត្រូវចោទ | សហព្រះរាជអាជ្ញា | អ្នកបកប្រែ | ក្រឡាបញ្ជី | សហចៅក្រមស៊ើបអង្កេត |
|---|---|---|---|---|---|
| **Charged Person** | **Lawyer of Charged person** | **Co-Prosecutors** | **Interpreters** | **Greffiers** | **Co- Investigating Judges** |
| **Personne mise en examen** | **Avocat de la Personne mise en examen** | **Co-procureurs** | **Interprètes** | | **Co-juges d'instruction** |